សម្រាប់ Knox-Keene Plans (NOA)

# "សិទ្ធិរបស់អ្នក"

## សិទ្ធិរបស់អ្នក KNOX-KEENE
## នៅក្រោមគម្រោងថែទាំដែលស្ថិតក្រោមការគ្រប់គ្រងដោយ DENTAL

---

ប្រសិនបើអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចដែលគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកបានធ្វើឡើងសម្រាប់ការថែទាំសុខភាពមាត់ធ្មេញរបស់អ្នកទេនោះ លោកអ្នកអាចស្នើសុំគម្រោងសុខភាពមាត់ធ្មេញរបស់អ្នកដាក់បណ្តឹងឧទ្ធរណ៍បាន។

<u>តើខ្ញុំស្នើសុំបណ្តឹងឧទ្ធរណ៍មួយតាមរបៀបណា?</u>

អ្នកមានរយៈពេល 60 ថ្ងៃ គិតចាប់ពីថ្ងៃចេញលិខិតជូនដំណឹងអំពីចំណាត់ការនេះ ដើម្បីស្នើសុំដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ ប្រសិនបើគម្រោងសុខភាពមាត់ធ្មេញរបស់អ្នកបានសម្រេចកាត់បន្ថយពន្យារពេល ឬបញ្ចប់សេវាកម្ម ដែលអ្នកកំពុងទទួលបាននាពេលនេះ នោះអ្នកប្រហែលជាអាចបន្តការទទួលបានសេវាកម្មនេះទៀត រហូតដល់បណ្តឹងឧទ្ធរណ៍របស់អ្នកត្រូវបានសម្រេច។ ករណីនេះត្រូវបានគេហៅថា Aid Paid Pending។ ដើម្បីឱ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់ទទួលបាន Aid Paid Pending អ្នកត្រូវតែស្នើសុំគម្រោងសុខភាពមាត់ធ្មេញរបស់អ្នកសម្រាប់បណ្តឹងឧទ្ធរណ៍មួយក្នុងរយៈពេល 10 ថ្ងៃគិតចាប់ពីថ្ងៃចេញលិខិតជូនដំណឹងអំពីចំណាត់ការ ឬមុនកាលបរិច្ឆេទដែលគម្រោងសុខភាពមាត់ធ្មេញរបស់អ្នកសម្រេចថា ការផ្លាស់ប្តូរទៅកាន់សេវាកម្មរបស់អ្នកនឹងមានប្រសិទ្ធភាព។ ទោះបីជាគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកត្រូវតែផ្តល់ជូនអ្នកនូវ Aid Paid Pending ក៏ដោយ ក៏ពេលអ្នកស្នើសុំបណ្តឹងឧទ្ធរណ៍មួយនៅក្នុងរយៈពេលខាងលើទាំងនេះអ្នកគួរប្រាប់គម្រោងសុខភាពមាត់ធ្មេញរបស់អ្នកឱ្យដឹង នៅពេលអ្នកស្នើសុំបណ្តឹងឧទ្ធរណ៍មួយថាអ្នកចង់ទទួលបាន Aid Paid Pending រហូតដល់បណ្តឹងឧទ្ធរណ៍របស់អ្នកត្រូវបានសម្រេច។

ប្រសិនបើលោកអ្នកខកខាននៅក្នុងរយៈពេល 10 ថ្ងៃដើម្បីស្នើសុំបណ្តឹងឧទ្ធរណ៍មួយ ឬមិនស្នើសុំបណ្តឹងឧទ្ធណ៍មួយ នៅមុនកាលបរិច្ឆេទដែលការផ្លាស់ប្តូរទៅកាន់សេវាកម្មរបស់អ្នកនឹងមានប្រសិទ្ធភាព នោះលោកអ្នកនៅមានពេល 60 ថ្ងៃទៀត គិតចាប់ពីថ្ងៃចេញលិខិតជូនដំណឹងអំពីចំណាត់ការនេះ ដើម្បីស្នើសុំបណ្តឹងឧទ្ធរណ៍មួយ។ ប៉ុន្តែ លោកអ្នកនឹងមិនទទួលបាន Aid Paid Pending ខណៈពេលដែលបណ្តឹងឧទ្ធរណ៍របស់លោកអ្នកកំពុងត្រូវបានសម្រេចនោះទេ។

លោកអ្នកអាចស្នើសុំបណ្តឹងឧទ្ធរណ៍មួយដោយខ្លួនឯងបាន។ ឬលោកអ្នកអាចឱ្យនរណាម្នាក់ដូចជាសាច់ញាតិ មិត្តភក្តិ អ្នកតស៊ូមតិ ទន្តពេទ្យ ឬមេធាវីស្នើសុំបណ្តឹងឧទ្ធរណ៍មួយជំនួសឱ្យរូបអ្នកបាន។ គេហៅបុគ្គលរូបនេះថា ជាអ្នកតំណាងដែលមានការអនុញ្ញាត។ គម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកអាចផ្តល់ទម្រង់បែបបទមួយដើម្បីឱ្យអ្នកកំណត់អ្នកតំណាងដែលមានការអនុញ្ញាតរបស់លោកអ្នក។ លោកអ្នកឬអ្នកតំណាងដែលមានការអនុញ្ញាតរបស់លោកអ្នកអាចដាក់ស្នើគ្រប់យ៉ាងដែលលោកអ្នកចង់ឱ្យគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកពិនិត្យមើលដើម្បីធ្វើការសម្រេចនៅលើបណ្តឹងឧទ្ធរណ៍របស់លោកអ្នក។ ទន្តពេទ្យដែលខុសពីទន្តពេទ្យធ្វើការសម្រេចចិត្តមុនដំបូង នឹងពិនិត្យមើលបណ្តឹងឧទ្ធរណ៍របស់លោកអ្នក។

សម្រាប់ Knox-Keene Plans (NOA)

លោកអ្នកអាចដាក់ពាក្យបណ្ដឹងឧទ្ធរណ៍តាមរយៈទូរសព្ទ ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិកៈ

- តាមទូរសព្ទ៖ ទាក់ទង Health Net Dental ចន្លោះម៉ោង 8:00 ព្រឹក ដល់ 5:00 ល្ងាច ដោយទូរសព្ទទៅលេខ 1-844-233-4522។ ប្រសិនបើលោកអ្នកមិនអាចស្ដាប់ ឬនិយាយមិនសូវល្អ សូមហៅទូរសព្ទទៅលេខ 1-844-233-4522។

- ជាលាយលក្ខណ៍អក្សរ៖ បំពេញទម្រង់បណ្ដឹងឧទ្ធរណ៍ ឬសរសេរលិខិតមួយ ហើយផ្ញើទៅ៖

  Appeals and Grievances Department
  P.O. Box 10348
  Van Nuys, CA 91410-0348

  ទូរសារ៖ 1-877-713-6189

  ការិយាល័យទន្តពេទ្យរបស់លោកអ្នកនឹងមានផ្ដល់ជូនលោកអ្នកនូវទម្រង់បែបបទបណ្ដឹងឧទ្ធរណ៍។ គម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកក៏អាចផ្ញើទម្រង់បែបបទដល់លោកអ្នកផងដែរ។

- អេឡិចត្រូនិក៖ ចូលមើលគេហទំព័រគម្រោងសុខភាពធ្មេញរបស់អ្នក។ ចូលទៅគេហទំព័រ www.healthnet.com។

---

<u>តើបណ្ដឹងឧទ្ធរណ៍របស់ខ្ញុំនឹងត្រូវបានសម្រេចនៅពេលណា?</u>

សម្រាប់បណ្ដឹងឧទ្ធរណ៍ស្តង់ដា គម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកត្រូវតែឆ្លើយតបទៅកាន់បណ្ដឹងឧទ្ធរណ៍របស់លោកអ្នកជាលាយលក្ខណ៍អក្សរនៅក្នុងរយៈពេល 30 ថ្ងៃ។ ប្រសិនបើលោកអ្នកគិតថា ការរង់ចាំ 30 ថ្ងៃនឹងប៉ះពាល់ដល់សុខភាពរបស់លោកអ្នក នោះលោកអ្នកប្រហែលជាអាចទទួលបានសេចក្តីសម្រេចមួយក្នុងរយៈពេល 72 ម៉ោងបាន។ នៅពេលលោកអ្នកស្នើសុំបណ្ដឹងឧទ្ធរណ៍ជាមួយនឹងគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកនោះ សូមនិយាយពីមូលហេតុដែលការរង់ចាំនោះនឹងធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់លោកអ្នក។ ត្រូវប្រាកដថាលោកអ្នកស្នើសុំបណ្ដឹងឧទ្ធរណ៍ដែលមានការពន្លឿន។

សម្រាប់បណ្ដឹងឧទ្ធរណ៍ដែលមានការពន្លឿន គម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកត្រូវតែព្យាយាមផ្តល់ជូនលោកអ្នកនូវការជូនដំណឹងផ្ទាល់មាត់ពីសេចក្តីសម្រេចរបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់លោកអ្នក។ សម្រាប់បណ្ដឹងឧទ្ធរណ៍ស្តង់ដា និងបណ្ដឹងឧទ្ធរណ៍ដែលមានការពន្លឿន គម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកនឹងផ្ញើលិខិតជូនដំណឹងពីសេចក្តីសម្រេចលើបណ្ដឹងឧទ្ធរណ៍មួយទៅតាមប្រៃសណីយ៍ជូនលោកអ្នក។ លិខិតនេះនឹងប្រាប់លោកអ្នកពីអ្វីដែលគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកបានសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់លោកអ្នក។

## តើខ្ញុំអាចស្នើសុំការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យមួយ និងសវនាការរដ្ឋមួយបានដែរឬទេ?

ការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យ គឺជាពេលដែលពេទ្យធ្មេញដែលមិនជាប់ទាក់ទងនឹងគម្រោងសុខភាពមាត់ធ្មេញនេះនឹងពិនិត្យមើលបណ្តឹងរបស់លោកអ្នក។ សវនាការរដ្ឋ គឺនៅពេលដែលចៅក្រមនឹងពិនិត្យមើលបណ្តឹងរបស់លោកអ្នក។

ប្រសិនបើលោកអ្នកមិនយល់ស្របនឹងសេចក្តីសម្រេចនៃគម្រោងសុខភាពរបស់លោកអ្នកទាក់ទងនឹងសេវាកម្មរបស់លោកអ្នកទេ លោកអ្នកអាចស្នើសុំគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកសម្រាប់បណ្តឹងឧទ្ធរណ៍មួយ។ ប្រសិនបើលោកអ្នកនៅតែមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកទៅលើបណ្តឹងឧទ្ធរណ៍របស់លោកអ្នកទៀត ឬវាមានរយៈពេលយ៉ាងតិច 30 ថ្ងៃហើយចាប់ពីអ្នកបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍របស់លោកអ្នកទៅកាន់គម្រោងសុខភាពមាត់ធ្មេញរបស់អ្នក នោះអ្នកអាចស្នើសុំការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យមួយជាមួយនឹងក្រសួងថែទាំសុខភាពដែលស្ថិតក្រោមការគ្រប់គ្រង (DMHC)។ បុគ្គលិក DMHC នឹងកំណត់ ថាតើបញ្ហារបស់លោកអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យមួយឬអត់។

នៅក្នុងករណីភាគច្រើន អ្នកមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីស្នើសុំសវនាការរដ្ឋទេរហូតទាល់តែលោកអ្នកបានបញ្ចប់ដំណើរការបណ្តឹងឧទ្ធរណ៍ផ្ទៃក្នុងរបស់គម្រោងសុខភាពមាត់ធ្មេញរបស់អ្នកជាមុនសិន។ ប៉ុន្តែ មានពេលខ្លះ ដែលលោកអ្នកអាចស្នើសុំសវនាការរដ្ឋដោយផ្ទាល់បាន។ ករណីនេះអាចកើតឡើង ប្រសិនបើគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកមិនបានជូនដំណឹងដល់អ្នកឱ្យបានត្រឹមត្រូវ ឬទាន់ពេលស្តីពីសេវាកម្មរបស់អ្នក។ ករណីនេះហៅថាការចាត់ទុកថាអស់ដំណោះស្រាយ។ ទាំងនេះគឺជាឧទាហរណ៍មួយចំនួននៃការចាត់ទុកថាអស់ដំណោះស្រាយៈ

- គម្រោងសុខភាពមាត់ធ្មេញនេះមិនបានចេញលិខិតជូនដំណឹងអំពីចំណាត់ការដល់លោកអ្នកជាភាសាដែលលោកអ្នកចង់បាន។
- គម្រោងសុខភាពមាត់ធ្មេញនេះបានបង្កើតកំហុស ដែលប៉ះពាល់ដល់សិទ្ធិណាមួយរបស់លោកអ្នក។
- គម្រោងសុខភាពមាត់ធ្មេញនេះមិនបានផ្តល់ជូនលោកអ្នកនូវលិខិតជូនដំណឹងអំពីចំណាត់ការជាលាយលក្ខណ៍អក្សរ ដែលជម្រាបលោកអ្នកពីចំណាត់ការតាមបំណងរបស់ខ្លួនទាក់ទងនឹងសេវាកម្មរបស់លោកអ្នកឡើយ។
- គម្រោងសុខភាពមាត់ធ្មេញនេះបានបង្កើតកំហុសនៅក្នុងលិខិតជូនដំណឹងអំពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួន។
- គម្រោងសុខភាពមាត់ធ្មេញនេះមិនបានសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោកអ្នកនៅក្នុងរយៈពេល 30 ថ្ងៃ និងមិនបានផ្ញើជូនលោកអ្នកនូវលិខិតជូនដំណឹងអំពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍មួយទេ។
- គម្រោងសុខភាពមាត់ធ្មេញនេះបានសម្រេចថា បណ្តឹងរបស់លោកអ្នកជារឿងបន្ទាន់ ប៉ុន្តែមិនបានឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍របស់លោកអ្នកក្នុងរយៈពេល 72 ម៉ោងហើយមិនបានផ្ញើជូនលោកអ្នកនូវលិខិតជូនដំណឹងអំពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍មួយទេ។

ពេលខ្លះ លោកអ្នកអាចស្នើសុំទាំងការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យ និងសវនាការរដ្ឋក្នុងពេលតែមួយបាន។ លោកអ្នកក៏អាចស្នើសុំចំណាត់ការមួយ នៅមុនមួយទៀត ដើម្បីពិនិត្យមើល ថាតើវានឹងដោះស្រាយបញ្ហារបស់លោកអ្នកបានមុនគេឬអត់។ ឧទាហរណ៍ ប្រសិនបើដំបូងលោកអ្នកស្នើសុំការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យ ប៉ុន្តែមិនយល់ស្របនឹងអ្វីដែលបានសម្រេចទេ នោះលោកអ្នកអាចស្នើសុំសវនាការរដ្ឋនៅពេលក្រោយបាន។ ប៉ុន្តែ ប្រសិនបើដំបូង

សម្រាប់ Knox-Keene Plans (NOA)

លោកអ្នកស្នើសុំសវនាការរដ្ឋ ប៉ុន្តែសវនាការរបស់អ្នកបានកើតឡើងរួចហើយ នោះលោកអ្នកមិនអាចស្នើសុំការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យបានទេ។ ក្នុងករណីនេះ សវនាការរដ្ឋមានអំណាចសម្រេចចុងក្រោយ។

លោកអ្នកនឹងមិនចាំបាច់បង់ប្រាក់សម្រាប់សេវាពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យ ឬសវនាការរដ្ឋនោះទេ។

---

## តើខ្ញុំស្នើសុំការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យតាមរបៀបណា?

កថាខណ្ឌខាងក្រោមផ្តល់ជូនលោកអ្នកនូវព័ត៌មានស្តីពីរបៀបស្នើសុំការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យជាមួយនឹង DMHC។ [1] ចំណាំថាពាក្យបណ្តឹងសាទុក្ខ សំដៅដល់បណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍៖

"ក្រសួងថែទាំសុខភាពដែលគ្រប់គ្រងដោយ California ទទួលខុសត្រូវក្នុងការគ្រប់គ្រងគម្រោងសេវាថែទាំសុខភាព។ ប្រសិនបើអ្នកមានការជំទាស់ប្រឆាំងនឹងគម្រោងសុខភាពមាត់ធ្មេញរបស់អ្នក ដំបូងលោកអ្នកគួរតែទាក់ទងគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នកតាមរយៈលេខ 1-844-233-4522 និងប្រើនីតិវិធីបណ្តឹងសាទុក្ខរបស់គម្រោងសុខភាពមាត់ធ្មេញរបស់អ្នកមុននឹងទាក់ទងក្រសួង។ ការប្រើប្រាស់នីតិវិធីបណ្តឹងសារទុក្ខនេះមិនបានបិទសិទ្ធិ ឬដំណោះស្រាយផ្នែកច្បាប់ទាំងឡាយដែលអាចមានសម្រាប់អ្នកទេ។ ប្រសិនបើលោកអ្នកត្រូវការជំនួយដើម្បីដាក់បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងការសង្គ្រោះបន្ទាន់ បណ្តឹងសារទុក្ខដែលមិនបានដោះស្រាយប្រកបដោយការមិនពេញចិត្តពីគម្រោងសុខភាពមាត់ធ្មេញរបស់លោកអ្នក ឬបណ្តឹងសារទុក្ខដែលមិនទាន់បានដោះស្រាយលើសពី 30 ថ្ងៃ នោះលោកអ្នកអាចហៅទូរសព្ទទៅក្រសួងនេះដើម្បីស្នើសុំជំនួយបាន។ លោកអ្នកក៏អាចមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការពិនិត្យមើលផ្នែកវេជ្ជសាស្ត្រដោយឯករាជ្យ (IMR) ផងដែរ។ ប្រសិនបើលោកអ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ IMR នោះដំណើរការ IMR នឹងផ្តល់ការពិនិត្យមើលដោយមិនលំអៀងលើសេចក្តីសម្រេចខាងវេជ្ជសាស្ត្រដែលធ្វើឡើងដោយគម្រោងសុខភាពមាត់ធ្មេញណាមួយទាក់ទងទៅនឹងភាពចាំបាច់ខាងវេជ្ជសាស្ត្រនៃសេវាកម្ម ឬការព្យាបាលដែលបានស្នើសុំ សេចក្តីសម្រេចលើការធានារ៉ាប់រងសម្រាប់ការព្យាបាលដែលជាលក្ខណៈពិសោធន៍ ឬស៊ើបអង្កេត និងវិវាទនៃការបង់ប្រាក់សម្រាប់សេវាវេជ្ជសាស្ត្រក្នុងគ្រាអាសន្ន ឬសង្គ្រោះបន្ទាន់។ ក្រសួងក៏មានលេខទូរសព្ទឥតគិតថ្លៃផងដែរ **(1-888-466-2219)** និងខ្សែទូរសព្ទ TDD **(1-877-688-9891)** សម្រាប់អ្នកដែលមានការចុះខ្សោយការស្តាប់ និងការនិយាយស្តី។ គេហទំព័រលើអ៊ីនធឺណិតរបស់ក្រសួង https://www.dmhc.ca.gov/ មានទម្រង់បែបបទពាក្យបណ្តឹង ពាក្យសុំ IMR និងការណែនាំនៅលើប្រព័ន្ធអនឡាញ។

---

## តើខ្ញុំស្នើសុំសវនាការរដ្ឋតាមរបៀបណា?

ដូចបានរៀបរាប់ខាងលើ លោកអ្នកអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីស្នើសុំសវនាការរដ្ឋមួយបាន។

---

[1] ផ្នែកលេខកូដសុវត្ថិភាព និងសុខភាព (HSC) 1368.02(b)។ HSC អាចស្វែងរកបាននៅ៖ https://leginfo.legislature.ca.gov/faces/codesTOCSelected.xhtml

សម្រាប់ Knox-Keene Plans (NOA)

លោកអ្នកអាចស្នើសុំសវនាការរដ្ឋតាមរបៀបដូចតទៅនេះបាន៖

- តាមអនឡាញនៅ https://www.cdss.ca.gov/

- តាមទូរសព្ទ៖ ហៅទៅលេខ 1-800-743-8525។ លេខទូរសព្ទនេះអាចមមាញឹកខ្លាំង។ លោកអ្នកអាចនឹងទទួលបានសារមួយដើម្បីឱ្យហៅទូរសព្ទត្រឡប់មកវិញនៅពេលក្រោយ។ ប្រសិនបើលោកអ្នកមិនអាចនិយាយ ឬស្តាប់មិនសូវល្អទេ សូមហៅទូរសព្ទទៅកាន់ TTY/TDD 1-800-952-8349។

- ជាលាយលក្ខណ៍អក្សរ៖ បំពេញទម្រង់បែបបទសវនាការរដ្ឋ ឬសរសេរសំបុត្រ។ ផ្ញើទៅតាមប្រៃសណីយ៍ ឬផ្ញើទូរសារទៅកាន់៖

  Mail: California Department of Social Services
  State Hearings Division
  P.O. Box 944243, Mail Station 9-17-37
  Sacramento, CA 94244-2430

  ទូរសារ៖ (916) 309-3487 ឬទូរស័ព្ទឥតគិតថ្លៃនៅ 1-833-281-0903

ទម្រង់បែបបទសវនាការរដ្ឋត្រូវបានរួមបញ្ចូលជាមួយនឹងលិខិតនេះ។ ត្រូវប្រាកដថាបានបញ្ចូលឈ្មោះ អាសយដ្ឋាន លេខទូរសព្ទ លេខសន្តិសុខសង្គម និង/ឬ លេខ CIN និងហេតុផលដែលលោកអ្នកចង់បានសវនាការរដ្ឋ។ ប្រសិនបើមាននរណាម្នាក់កំពុងជួយលោកអ្នកស្នើសុំសវនាការរដ្ឋ សូមបន្ថែមឈ្មោះ អាសយដ្ឋាន និងលេខទូរសព្ទរបស់ពួកគេទៅក្នុងទម្រង់បែបបទ ឬលិខិតនោះ។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ សូមជម្រាបជូនផ្នែកសវនាការរដ្ឋនូវភាសាដែលអ្នកនិយាយ។ អ្នកនឹងមិនចាំបាច់ចំណាយប្រាក់សម្រាប់អ្នកបកប្រែផ្ទាល់មាត់ទេ។ ផ្នែកសវនាការរដ្ឋនឹងផ្តល់ជូនអ្នកនូវអ្នកបកប្រែផ្ទាល់មាត់មួយរូប។ ប្រសិនបើអ្នកមានពិការភាពណាមួយ ផ្នែកសវនាការរដ្ឋអាចផ្តល់ជូនលោកអ្នកនូវការសម្របតាមតម្រូវការរបស់អ្នកដោយឥតគិតថ្លៃ ដើម្បីជួយឱ្យអ្នកចូលរួមក្នុងសវនាការនេះ។ សូមរួមបញ្ចូលព័ត៌មានស្តីពីពិការភាពរបស់លោកអ្នក និងការសម្របតាមតម្រូវការ ដែលអ្នកត្រូវការ។

បន្ទាប់ពីលោកអ្នកស្នើសុំសវនាការរដ្ឋ វាអាចចំណាយពេលរហូតដល់ទៅ 90 ថ្ងៃ ដើម្បីសម្រេចបណ្តឹងរបស់អ្នក និងផ្ញើចម្លើយមកជូនអ្នក។ ប្រសិនបើអ្នកគិតថា ការរង់ចាំ 90 ថ្ងៃនឹងធ្វើឱ្យប៉ះពាល់ដល់សុខភាពលោកអ្នក អ្នកអាចស្នើសុំសវនាការដែលមានការពន្លឿនមួយបាន។ ប្រសិនបើផ្នែកសវនាការថ្នាក់រដ្ឋយល់ព្រមលើការស្នើសុំសវនាការដែលមានការពន្លឿនមួយ លោកអ្នកប្រហែលជាអាចទទួលបានសម្រេចពីសវនាការនៅក្នុងរយៈពេល 3 ថ្ងៃចាប់ពីថ្ងៃដែលផ្នែកទទួលបានពាក្យបណ្តឹងរបស់អ្នកពីគម្រោងសុខភាពមាត់ធ្មេញរបស់អ្នក។

លោកអ្នកអាចស្នើសុំសវនាការដែលមានការពន្លឿនមួយបានដោយការហៅទូរសព្ទទៅកាន់ផ្នែកសវនាការរដ្ឋតាមលេខខាងលើ។ ឬអ្នកអាចផ្ញើទម្រង់បែបបទសវនាការរដ្ឋ ឬលិខិតមួយទៅកាន់ផ្នែកសវនាការរដ្ឋនេះបាន។ លោកអ្នកត្រូវតែពន្យល់ថា តើការរង់ចាំការសម្រេចរបស់លោកអ្នករហូតដល់ 90 ថ្ងៃនឹងធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត សុខភាព ឬសមត្ថភាពរបស់លោកអ្នកក្នុងការទទួលបាន ឬថែរក្សាការបំពេញមុខងារអតិបរមារបស់លោកអ្នកយ៉ាងណា។ លោកអ្នកក៏អាចទទួលបានលិខិតមួយពីពេទ្យធ្មេញរបស់អ្នកដើម្បីជួយបង្ហាញពីមូលហេតុដែលអ្នកត្រូវការសវនាការដែលមានការពន្លឿនមួយ។

សម្រាប់ Knox-Keene Plans (NOA)

អ្នកអាចនិយាយឱ្យខ្លួនឯងនៅសវនាការរដ្ឋនេះបាន។ ឬលោកអ្នកអាចមាននរណាម្នាក់ដូចជាសាច់ញាតិ មិត្តភក្តិ អ្នកតស៊ូមតិ ពេទ្យធ្មេញ ឬមេធាវីនិយាយជំនួសឱ្យរូបអ្នកបាន។ ប្រសិនបើអ្នកចង់ឱ្យបុគ្គលម្នាក់ផ្សេងទៀតនិយាយជំនួសឱ្យ រូបអ្នក នោះលោកអ្នកត្រូវតែចុះហត្ថលេខាលើទម្រង់បែបបទមួយដែលជម្រាបជូនផ្នែកសវនាការរដ្ឋថាបុគ្គលនោះអាចនិយាយជំនួសឱ្យរូបអ្នកបាន។ គេហៅបុគ្គលរូបនេះថា ជាអ្នកតំណាងដែលមានការអនុញ្ញាត។

<u>ជំនួយផ្នែកច្បាប់</u>

លោកអ្នកប្រហែលជាអាចទទួលបានជំនួយផ្នែកច្បាប់ឥតគិតថ្លៃបាន។ ហៅទូរសព្ទទៅ

| Entity Name | Telephone | County Served |
|---|---|---|
| Legal Services of Northern California | (888) 354-4474 | Alpine, Amador, Butt, Calaveras, Colusa, El Dorado, Glenn, Inyo, Mono, Nevada, Placer, Plumas, Sacramento, San Joaquin, Sierra, Sutter, Tehama, Yuba |
| Greater Bakersfield Legal Assistance, Inc. | (888) 292-4252 | Kern |
| Central California Legal Services, Inc. | (559) 570-1200 | Fresno, Kings, Madera, Mariposa, Stanislaus, Tulare, Tuolumne |
| California Rural Legal Assistance, Inc. | (760) 353-0220 | Imperial |
| Legal Aid Foundation of Los Angeles | (800) 399-4529 | Los Angeles |
| Legal Aid Society of San Diego | (877) 534-2524 | San Diego |

អ្នកក៏អាចហៅទូរសព្ទទៅកាន់ការិយាល័យជំនួយផ្លូវច្បាប់នៅក្នុងខោនធីរបស់អ្នកតាមលេខ 1-888-804-3536 បានផងដែរ។